**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ : ១១/២០**

**បានពិនិត្យត្រឹមត្រូវ**
**អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលផ្លូវរត់ទំហំ ៩.២០០ម២ នៅអាកាសយានដ្ឋានបាត់ដំបង

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលផ្លូវរត់ទំហំ ៩.២០០ម២ នៅអាកាសយានដ្ឋានបាត់ដំបង។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានអាសយដ្ឋានលេខៈ ៤៤, មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន,សង្កាត់ កាកាប,ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..១៣..ខែ...កក្កដា...ឆ្នាំ ២០២០ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ ០២៣ ៨៩០ ១៦៣) ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣..ខែ.សីហា ឆ្នាំ ២០២០ វេលាម៉ោងៈ........៩:០០............។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោងៈ.៩:៣០ ............ថ្ងៃទី.១៣..ខែ..សីហា..ឆ្នាំ ២០២០។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃអង្គារ..១៤.កើត.ខែ....អាសាឍ.....ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៤..ខែ.កក្កដា...ឆ្នាំ ២០២០
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ